YUNNAN DAILY PRESS GROUP
云南日报报业集团
No.195

# ប្រទេសចិន-ខេត្តយូនណាន

ទស្សនាវដ្ដីប្រចាំថ្ងៃ

klmerlight@163.com
yunnangateway.com
Follow Amazing Yunnan on Facebook

ឆ្នាំទី27 លេខ8019 ថ្ងៃសុក្រ ទី30 ខែសីហា ឆ្នាំ2019

## ខេត្តយូនណានរក្សាកំណើនសេដ្ឋកិច្ចដែលមានល្បឿនយ៉ាងលឿន

ក្នុងអំឡុងពេលពីខែមករា ដល់ខែកក្កដា ឆ្នាំ២០១៩ នេះ ខេត្តយូនណាន បានសម្រេចពាណិជ្ជកម្មនាំចេញ នាំចូល ដែលមានទំហំសរុប ១២៥.៨៣០លានយ័នប្រាក់ចិន (ស្មើនឹង១៨.៥១០លានដុល្លារអាម៉េរិក) កើនឡើង១៧,៩ភាគរយ បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០១៨ ។ ពាណិជ្ជកម្មអន្តរជាតិខេត្តយូនណាន បានបង្ហាញពីលក្ខណៈពិសេសមួយចំនួន ដូចជាមានកិច្ចសហប្រតិបត្តិការកាន់តែស្អិតល្មួតជាមួយប្រទេសតាមបណ្តោយ"ខ្សែក្រវាត់មួយនិងផ្លូវមួយ" គ្របដណ្តប់លើវិស័យកាន់តែច្រើននិងធ្វើសាមញ្ញកម្មកាន់តែស៊ីជម្រៅលើវិស័យពាណិជ្ជកម្មជាដើម ។



*ម៉ូតូដែលផលិតនៅ តំបន់ឧស្សាហកម្មផលិតម៉ូតូ យីនស្យេង ក្រុងយូយលី មានចំនួន ៩០ភាគរយ ត្រូវនាំចេញទៅប្រទេសមីយ៉ាន់ម៉ា*

ទន្ទឹមនឹងការកសាង"ខ្សែក្រវាត់មួយនិងផ្លូវមួយ" ខេត្តយូនណាន បានពង្រឹងឱ្យកាន់តែស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការផ្នែកពាណិជ្ជកម្មជាមួយប្រទេស"ខ្សែក្រវាត់មួយនិងផ្លូវមួយ"។ ក្នុងអំឡុងពេលពីខែមករាដល់ខែកក្កដា ឆ្នាំ២០១៩ ពាណិជ្ជកម្មរវាងខេត្តយូនណាននិងប្រទេស"ខ្សែក្រវាត់មួយនិងផ្លូវមួយ"មានទំហំ៩០.៧៤០លានយ័ន កើនឡើង១៦ភាគរយ ត្រូវជា៧២,១ភាគរយ នៃទំហំពាណិជ្ជកម្មនាំចេញ នាំចូលសរុបរបស់ខេត្តយូន-ណាន។ ក្រៅពីនេះ ក្នុងរយៈពេលទាំង៧ខែនោះ ពាណិជ្ជកម្មរវាងខេត្តយូនណាននិងប្រទេសអាស៊ានមាន ទំហំ៦៣.០១០លានយ័ន កើនឡើង២០ភាគរយចំណែកទំហំពាណិជ្ជកម្មរវាងខេត្តយូនណាននិងប្រទេសអាស៊ីខាងត្បូងបានកើនឡើង៣៣ភាគរយ ។

ខេត្តយូនណាន មិនគ្រាន់តែបានរក្សាកំណើនពាណិជ្ជកម្មអន្តរជាតិដែលមានល្បឿនយ៉ាងលឿនប៉ុណ្ណោះទេ ថែមទាំងបានគ្របដណ្តប់លើវិស័យពិសេសកាន់តែច្រើនទៀតផង ។ ក្នុងនោះពាណិជ្ជកម្មកសិផលបានក្លាយទៅជាចំណុចពិសេសដ៏សំខាន់នៃពាណិជ្ជ-កម្មអន្តរជាតិខេត្តយូនណាន ។ ប៉ុន្មានខែមុន "ទិវាផ្លែឈើល្អរបស់ប្រទេសថៃ" បានត្រូវរៀបចំនៅក្នុងក្រុងគុនមីង នៃខេត្តយូនណាន ។ មង្ឃុតទុរេននិងក្រូចត្លុងរបស់ប្រទេសថៃ បានទទួលការពេញនិយមពីអតិថិជនចិន ។ ក្រូចអន្តរ-ជាតិម៉កហានដែលមានចម្ងាយជាង៦៨០គីឡូម៉ែត្រពីក្រុងគុនមីងនោះ ជាក្រុចអន្តរជាតិសំខាន់មួយសម្រាប់ការនាំចូលផ្លែឈើថៃមកប្រទេសចិន។ នៅឆមាសទី១ នៃឆ្នាំ២០១៩ បរិមាណ និងតម្លៃពាណិជ្ជកម្មនៃការនាំចូលផ្លែឈើថៃតាមច្រកអន្តរជាតិម៉កហានបានកើនឡើងប្រហែលទ្វេដង ។

ដោយសារខេត្តយូនណាន មានទីតាំងភូមិសាស្ត្រដ៏មានឧត្តមភាព ហើយមានទំនាក់ទំនងពាណិជ្ជកម្មល្អជាមួយប្រទេសជិតខាងខេត្តយូនណានបានក្លាយទៅជាច្រកសំខាន់សម្រាប់ការនាំចូលកសិផលបរទេសមកប្រទេសចិន ។ ទន្ទឹមនឹងនេះដែរកសិផលខេត្តយូនណានបានទទួលការពេញនិយមនៅក្រៅប្រទេសចិនដោយសារមានគុណភាពល្អនិងភាពបៃតង ។ តាមស្ថិតិពីស្ថាប័នគយ នៃក្រុងគុនមីង ក្នុងរយៈពេលពីខែមករា ដល់ខែកក្កដា ឆ្នាំ២០១៩ ខេត្តយូនណានបាននាំចេញកសិផលដែលមានទំហំពាណិជ្ជកម្មសរុប១៤.៤៨០លានយ័ន នាំចូលកសិផលបរទេស៦.៥៥០ លានយ័ន ។ ក្នុងនោះទំហំពាណិជ្ជកម្មនៃការនាំចេញផ្លែឈើបានកើនឡើង៤៨,៧ភាគរយ ចំណែកទំហំពាណិជ្ជកម្មនាំចូលផ្លែឈើបានកើនឡើង១,៣ដង ។

ប៉ុន្មានឆ្នាំនេះខេត្តយូនណាន បានខិតខំធ្វើសាមញ្ញកម្មនៃការបំពេញបែបបទឆ្លងដែនតាមច្រកអន្តរជាតិដើម្បីជំរុញការអភិវឌ្ឍពាណិជ្ជកម្មអន្តរជាតិ។ លោក ស្យេ គួង ធ្វើការនៅស្ថាប័នគយក្រុងយូយលីបាន១៨ ឆ្នាំហើយ ។ លោកបានរំលឹកឡើងវិញថា នៅពេលដំបូងដែលខ្ញុំចូលធ្វើការនៅស្ថាប័នគយច្រកអន្តរជាតិក្រុងយូយលីគ្មានទីលានស្តុកទំនិញដោយឡែកទេ ចំណែកក្រុមហ៊ុនដែលធ្វើអាជីវកម្មនាំចេញនាំចូលត្រូវបំពេញបែបបទឆ្លងដែននៅស្ថាប័នច្រើន។ ប៉ុន្តែរថយន្តដឹកទំនិញមួយគ្រឿងអាចឆ្លងការពិនិត្យឆ្លងដែនដោយ ចំណាយពេលតែ២-៣នាទីនាពេលបច្ចុប្បន្ន ។ លោកបន្តទៀតថា សព្វថ្ងៃ ហេដ្ឋារចនា-សម្ព័ន្ធនៅច្រកអន្តរជាតិ ក្រុងយូយលីក៏បានត្រូវកែលម្អជាច្រើនដោយបានដំឡើងគ្រឿងបរិក្ខារពិនិត្យ ដ៏ឿនលឿន និងប្រព័ន្ធបណ្តាញអ៊ីនធឺណិតហើយបានដាក់ឱ្យប្រើប្រាស់នូវ ប្រព័ន្ធបំពេញបែបបទអេឡិចត្រូនិក ។ វិធានការទាំងនេះបានជួយកាត់បន្ថយនូវដើមទុនរបស់ក្រុមហ៊ុនផ្សេងៗលើក កម្ពស់នូវប្រសិទ្ធ-ភាពនៃការធ្វើពាណិជ្ជកម្ម និងបានជំរុញការអភិវឌ្ឍនៃ ពាណិជ្ជកម្មអន្តរជាតិ ៕

## ឯកឧត្តមស៊ី ជីនភីង បកស្រាយពីការបើកចំហចំពោះបរទេស

"ប្រទេសចិនប្រកាន់ខ្ជាប់នូវគោលនយោបាយមូលដ្ឋានអំពីការបើកចំហចំពោះបរទេស ប្រកាន់ខ្ជាប់នូវគោលការណ៍អំពីការធ្វើការអភិវឌ្ឍន៍ដោយបើកទ្វារនៃប្រទេស ។ ខ្ញុំត្រូវជម្រាបភ្ញៀវគ្រប់រូបយ៉ាងច្បាស់លាស់ថា ប្រទេសចិនមិនបិទទ្វារដែលបានបើកទូលាយនោះទេ ហើយនឹងបើកទ្វារនៃប្រទេសឱ្យកាន់តែទូលំទូលាយ ។ ការអនុវត្តជាក់ស្តែងបានសបញ្ជាក់ថាប្រទេសចិនបានទទួលសមិទ្ធផលនៃការអភិវឌ្ឍសេដ្ឋកិច្ចរយៈពេល៤០ ឆ្នាំតាមរយៈការបើកចំហចំណែកការអភិវឌ្ឍសេដ្ឋកិច្ចដោយមានគុណភាពខ្ពស់របស់ប្រទេសចិននាពេលអនាគតក៏ត្រូវដំណើរការតាមរយៈការបើកចំហឱ្យកាន់តែស៊ីជម្រៅដែរ ៕

**(ដកស្រង់ចេញពីសុន្ទរកថារបស់ឯកឧត្តម ស៊ី ជីនភីង ប្រធានាធិបតីចិនដែលថ្លែងក្នុងពិធីបើកសម័យប្រជុំប្រចាំឆ្នាំ២០១៨នៃវេទិកាBOAO ទ្វីបអាស៊ីនៅថ្ងៃទី១០ខែមេសាឆ្នាំ២០១៨)**

## កម្មវិធី "ស្ពានភាសាចិន" បង្កើតស្ពានសម្រាប់ជំរុញការផ្លាស់ប្តូរវប្បធម៌



*បេក្ខជនឈ្មោះ លូ ម៉េងយ៉ានដែលមកពីប្រទេសអាម៉េរិកកំពុងសាកល្បងបច្ចេកទេសបោះពុម្ព ដោយប្រើតួអក្សរចល័តនៅក្រុងឈូហ្វូនៃខេត្តសានតុង*

យប់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩ការប្រកួតភាសាចិនសម្រាប់សិស្សមធ្យមសិក្សាពិភពលោក"ស្ពានភាសាចិន"លើកទី១៨ បានបិទបញ្ចប់ដោយជោគជ័យនៅក្រុងឆាងសានៃប្រទេសចិន ។ ការប្រកួតភាសាចិននេះត្រូវរៀបចំឡើងដើម្បីធ្វើការប្រកួតប្រជែងអំពីសមត្ថភាពភាសាចិននិងជំរុញការផ្លាស់ប្តូរផ្នែកវប្បធម៌បង្កើនទំនាក់ទំនងរវាងយុវជនចិននិងបរទេស ព្រមទាំងនិទានរឿងចិនឱ្យបានកាន់តែល្អប្រសើរ ។ ក្រោយពីត្រូវបានបង្កើតឡើងនៅឆ្នាំ២០០២ រៀងមកការប្រកួតនេះបានទាក់ទាញយុវជនបរទេសកាន់តែច្រើនពីមួយឆ្នាំទៅមួយឆ្នាំ ។ ពេលដំបូងបេក្ខជនបេក្ខនារីដែលចូលរួមការប្រកួតនេះមានតែ៥៩ នាក់ ហើយមកពីប្រទេសនិងតំបន់ចំនួន ២១ តែបច្ចុប្បន្នបេក្ខនជនបេក្ខនារីជាងមួយលាននាក់ដែលមកពីប្រទេស និងតំបន់ចំនួនជាង១៣០ បានចុះឈ្មោះដើម្បីចូលរួមការប្រកួតនេះ ។ ក្នុងនោះ មានបេក្ខជនបេក្ខនារីជាង៦០០០នាក់ បានត្រូវជ្រើសរើសឱ្យមកចូលរួមការប្រកួតផ្តាច់ព្រ័ត្រនៅប្រទេសចិន ៕

*(កាសែតប្រជាជន ដេលី)*

## បើកទ្វារនៃភូមិលើភ្នំឱបអរិយធម៌ទំនើប

មុននឹងប្រទេសចិនថ្មីត្រូវបានបង្កើតឡើង ជនជាតិគីណូដែលរស់នៅ ក្នុងឃុំភ្នំគីពូក្រុងជីងហុងមណ្ឌលស្វយ័ត ជន-ជាតិតៃស៊ីសាំងប៉ានណា ខេត្តយូនណាន នៅតែរស់នៅតាមរបៀបសម័យ បុរាណ ហើយមិនដែលស្គាល់ និងមានទស្សនៈអំពីទំនិញទេ។ ក្នុងរយៈពេល៧០ឆ្នាំកន្លងទៅនោះជនជាតិគីណូបានទទួលការរីកចម្រើនច្រើនគួរឱ្យកត់ សម្គាល់ ។ ជាពិសេសប៉ុន្មានឆ្នាំមកនេះជនជាតិគីណូចាប់ផ្តើមបើកទ្វារនៃភូមិ លើភ្នំដើម្បីឱបទទួលអរិយធម៌នៃសង្គម ទំនើប ។

ស៊ីសាំងប៉ានណាជាតំបន់ទេស-ចរណ៍ដ៏ល្បីល្បាញលើពិភពលោក។សព្វថ្ងៃភូមិប៉ាភួឃុំភ្នំគីណូ ដែលជាភូមិជន-ជាតិគីណូ ដ៏ចាស់បុរាណមួយបាន បង្កើតរមណីយដ្ឋានទេសចរណ៍ភ្នំគីណូ ។

ការអភិវឌ្ឍវិស័យទេសចរណ៍ បានជួយកាត់បន្ថយភាពក្រីក្ររបស់អ្នកភូមិ ។ លោក ឈឺ ជីហ្វូ បានប្រាប់អ្នកកាសែតថា រមណីយដ្ឋានទេសចរណ៍ភ្នំគីណូនឹងបែងចែកចំណេញដើម្បី ផ្តល់ជូនអ្នកភូមិជារៀងរាល់ឆ្នាំ។ ជាពិសេសរមណីយដ្ឋានទេសចរណ៍បានផ្តល់កន្លែងមួយចំនួនដោយមិនយកប្រាក់ជួលដើម្បីឱ្យអ្នកភូមិទៅលក់ផ្លែឈើ និងទឹកឃ្មុំ។ ក្រៅពីនេះអ្នកភូមិមួយចំនួនបានបើកភោជនីយដ្ឋាននិងផ្ទះសំណាក់នៅក្បែររមណីយដ្ឋានទេសចរណ៍ ។

ក្រៅពីការអភិវឌ្ឍវិស័យទេសចរណ៍តាមទីជនបទប្រជាជនជនជាតិគីណូបានចាប់ផ្តើមដាំកៅស៊ូ តែនិងផ្លែឈើគ្រប់មុខព្រមទាំងចិញ្ចឹមជ្រូក មាន់ទានិងឃ្មុំក្រោមការជួយឧបត្ថម្ភពីរដ្ឋបាលមូលដ្ឋានក្នុងតំបន់ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មទំនើបដែលមានលក្ខណៈពិសេសក្នុងតំបន់ ។

នៅខែមេសាឆ្នាំ ២០១៩ នេះ ជនជាតិគីណូបានកាត់បន្ថយភាពក្រីក្រទាំងស្រុង ។ បច្ចុប្បន្នគ្រប់ភូមិរបស់ជនជាតិគីណូសុទ្ធតែមានផ្លូវថ្នល់មានទឹកម៉ាស៊ីន និងមានភ្លើងអគ្គិសនី ចំណែកប្រជាជនបានទៅរស់នៅក្នុងលំនៅថ្មីហើយអាចមើលទូរទស្សន៍ប្រើបណ្តាញសេវា៤G និងទទួលសេវាកម្មសុខាភិបាលពេញលក្ខណៈ។ ជាពិសេសពួកគេបានអភិវឌ្ឍន៍មុខរបរពិសេសរបស់ខ្លួនចំណែកក្មេងៗមានឱកាសចូលសាលារៀនពិតជាមានសុភមង្គលណាស់៕

**ដោយលី ជឺលាំង (ស៊ុនហ្វចិន)**



*កុមារជនជាតិគីណូ ធំធាត់ឡើងដោយមានភាពសប្បាយ រីករាយ*

## "បន្តការសិក្សានៅប្រទេសចិនគឺជាការសម្រេចចិត្តត្រឹមត្រូវបំផុតដែលខ្ញុំធ្លាប់ធ្វើ"

លោកដុក ចិន្តា កើតនៅឆ្នាំ ១៩៨១ ជាយុវជនខ្មែរដែលបានរៀនសូត្រ និងធ្វើការនៅប្រទេសចិនជាង៥ឆ្នាំហើយ ។ ឆ្នាំទៅលោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតពីមុខវិជ្ជាគ្រប់គ្រងសេដ្ឋកិច្ចនៅសាកលវិទ្យាល័យវិទ្យាសាស្ត្រនិងបច្ចេក-ទេសវិទ្យាក្រុងគុនមីងហើយបានទទួលបរិញ្ញាប័ត្រជាន់ខ្ពស់ ដោយជោគជ័យ ។ បច្ចុប្បន្នលោកបានក្លាយទៅជាគ្រូបង្រៀនបរទេសមួយរូបដែលបង្រៀនភាសាខ្មែរនៅសាកលវិទ្យាល័យហុងហ៊ឺនៃខេត្តយូនណាន។លោកបានផ្តល់បទសម្ភាសន៍ជាមួយអ្នកកាសែតថា "ខ្ញុំស្រឡាញ់ប្រទេសកម្ពុជាស្រឡាញ់ប្រទេសចិន ហើយក៏ស្រឡាញ់ខេត្តយូនណានដែរ"។

ក្រោយពីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រនៅប្រទេសកម្ពុជាលោកដុក ចិន្តាធ្លាប់មានឱកាសទៅបន្តការសិក្សានៅសាកលវិទ្យាល័យនៃប្រទេសច្រើនលើពិភពលោក ។ ក៏ប៉ុន្តែបន្ទាប់ពីស្តាប់ការណែនាំរបស់មិត្តភក្តិដែលបន្តការសិក្សានៅខេត្តយូនណានលោកទើបសម្រេចចិត្តទៅបន្តការសិក្សានៅខេត្តយូនណាន ។ លោក ដុក ចិន្តា បានបញ្ជាក់ថា "ទៅបន្តការសិក្សានៅប្រទេសចិន គឺជាការសម្រេចចិត្តត្រឹមត្រូវបំផុតដែលខ្ញុំធ្លាប់ធ្វើ" ។ ខេត្តយូនណានមានអាកាសធាតុយ៉ាងល្អចំណែកបរិយាកាសនៃការសិក្សានៅទីនេះក៏បានធ្វើឱ្យលោកស្រឡាញ់ខេត្តយូនណានភ្លាមៗដែរ ។ ជាពិសេសលោកបានស្គាល់មិត្តល្អដ៏ច្រើនដែលមកពីប្រទេស និងតំបន់ផ្សេងៗលើពិភពលោក ។

លោកបានបញ្ជាក់ទៀតថា ទន្ទឹមនឹងការជំរុញការកសាង"ខ្សែក្រវាត់មួយ និងផ្លូវមួយ"ជាបន្តបន្ទាប់ កិច្ចសហប្រតិបត្តិការរវាងប្រទេសចិននិងកម្ពុជាក៏ត្រូវបានពង្រឹង និងពង្រីកឱ្យកាន់តែស៊ីជម្រៅផងដែរ ។ បើនិយាយចំពោះនិស្សិតខ្មែរដែលបន្តវិជ្ជានៅប្រទេសចិនមិនថា ត្រឡប់ទៅប្រទេសកម្ពុជាវិញឬស្នាក់នៅក្នុងប្រទេសចិនក្រោយពេលបញ្ចប់ការសិក្សាសុទ្ធតែមានឱកាសការងារដ៏ច្រើន ។ ទោះបីជាមានឱកាសការងារដ៏ច្រើនតែលោកដុកចិន្តាសម្រេចចិត្តធ្វើជាគ្រូបង្រៀនបរទេសនៅខេត្តយូន-ណាន ។ លោកបន្តទៀតថា "ខ្ញុំបានបើកកម្មវិធីអប់រំអំពីជនជាតិនៃប្រទេស កម្ពុជាដើម្បីណែនាំពីជនជាតិផ្សេងៗ របស់ប្រទេសកម្ពុជានិងវប្បធម៌ ប្រពៃណីខ្មែរដល់និស្សិតចិននិងធ្វើឱ្យនិស្សិតចិនមានការយល់ដឹងកាន់តែច្រើន និងកាន់តែស៊ីជម្រៅអំពីប្រទេស កម្ពុជា" ។

លោកដុក ចិន្តា មិនត្រឹមតែបានទទួលនូវចំណេះដឹងការងារ និងក្តីសុបិននៅប្រទេសចិនប៉ុណ្ណោះទេថែមទាំងបានទទួលនូវសេចក្តីស្នេហាឆ្លងដែនដ៏ផ្អែមល្ហែមទៀតផង ។ សង្សាររបស់លោកឈ្មោះ YEONJU ជាជនជាតិកូរ៉េខាងត្បូង ។ ក្រោមឥទ្ធិពលរបស់លោក កញ្ញា YEONJU កំពុងខិតខំរៀនភាសាចិនដើម្បីរកឱកាសមកបន្តការសិស្សានិងធ្វើការនៅប្រទេសចិននាពេលអនាគត ។ បំណងប្រាថ្នាធំបំផុតរបស់លោកនិងសង្សារលោកគឺអាចជួបជុំគ្នានៅប្រទេសចិនក្នុងពេលឆាប់ៗ ៕

**ដោយស៊ុន យ៉ាន**